ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

លេខ ១៣៤ បទ.ប្រក

និយ័តករទូរគមនាគមន៍កម្ពុជា

ចូល

លេខ [illegible] ន.ទ.ក

ថ្ងៃទី ០៣ ខែ ០៤ ឆ្នាំ២០១៦

ម៉ោង [illegible] បញ្ជូន

# ប្រកាស
# ស្តីពី
# ការកំណត់មុខងារនិងភារកិច្ចបន្ថែមរបស់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់និយ័តករទូរគមនាគមន៍
- បានឃើញប្រកាសលេខ ១២៦ បទ.ប្រក ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន មជ្ឈមណ្ឌល និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ ០៧២ បទ.ប្រក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍និងថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ
- បានឃើញប្រកាសលេខ ១៧៩ បទ.ប្រក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីអាជ្ញាប័ណ្ណបើកអាជីវកម្មសាលបម្រើអ៊ិនធឺណិត
- យោងតាមការចាំបាច់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍



កាច់ជ្រុងវិថីលេខ១១៣និង១០២សង្កាត់វត្តភ្នំខណ្ឌដូនពេញ

ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៨២៤៦

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីមុខងារនិងភារកិច្ចបន្ថែមរបស់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ (**មន្ទីរ ប.ទ.**)។

**ប្រការ២.-**

ពាក្យបច្ចេកទេសទាំងឡាយដែលប្រើប្រាស់ក្នុងប្រកាសនេះមានន័យដូចតទៅ៖

១-**លិខិតអនុញ្ញាត** សំដៅដល់លិខិតដែល **មន្ទីរ ប.ទ.** ផ្តល់ជូនអ្នកស្នើសុំដើម្បីបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិត បើកលក់ និង/ឬជួសជុលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ឬប្រើប្រាស់ហ្រេកង់ស៍ វីអេជ្យអែហ្វនិងយូអេជ្យអែហ្វ (VHF and UHF) សម្រាប់ដំណើរការស្ថានីយវិទ្យុទាក់ទងលើដីគោកក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន។

២-**វិទ្យុទាក់ទងលើដីគោក (Push To Talk)** សំដៅដល់បរិក្ខារសម្រាប់ទាក់ទងគ្នាលើដីគោកដោយប្រើរលកអាកាសវិទ្យុ វីអេជ្យអែហ្វនិងយូអេជ្យអែហ្វ (VHF and UHF)។

៣-**បង្គោលអង់តែន (Antenna Tower)** សំដៅដល់បង្គោលឬគ្រោងដែលត្រូវបានធ្វើឡើងដើម្បីបំពាក់អង់តែន។

៤-**វីអេជ្យអែហ្វ (VHF: Very High Frequency)** សំដៅដល់បន្ទារហ្វ្រេកង់ស៍វិទ្យុចាប់ពី ៣០ ទៅ ៣០០ ម៉េហ្គាហឺត (MHz)។

៥-**យូអេជ្យអែហ្វ (UHF: Ultra High Frequency)** សំដៅដល់បន្ទារហ្វ្រេកង់ស៍វិទ្យុចាប់ពី ៣០០ ម៉េហ្គាហឺត (MHz) ទៅ ៣ ជីហ្គាហឺត (GHz) ។

៦-**សាលបម្រើសេវាអ៊ិនធឺណិតកាហ្វេ (Internet café)** សំដៅដល់ទីកន្លែងបម្រើសេវាអ៊ិនធឺណិតផ្ទាល់ជូនដល់សាធារណជនប្រើប្រាស់អ៊ិនធឺណិត។

## ជំពូកទី២

## មុខងារនិងភារកិច្ចបន្ថែមរបស់មន្ទីរ ប.ទ.

**ប្រការ៣.-**

បុគ្គលទាំងឡាយត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនៅ **មន្ទីរ ប.ទ.** មានសមត្ថកិច្ច ដើម្បីបំពេញប្រតិបត្តិការដូចខាងក្រោម ៖

១-ការបើកអាជីវកម្មសាលបម្រើសេវាអ៊ិនធឺណិត។

២-ការបើកលក់និង/ឬជួសជុលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍។

៣-ការប្រើប្រាស់ហ្វ្រេកង់ស៍វិទ្យុវីអេជ្យអែហ្វនិងយូអេជ្យអែហ្វ ដោយគ្រឿងសម្ភារៈបរិក្ខារវិទ្យុទាក់ទងដែលមានអានុភាពផ្សាយមិនលើសពី៦០វ៉ាត់ (Watt) សម្រាប់ដំណើរការស្ថានីយវិទ្យុទាក់ទងលើដីគោកក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**ប្រការ៤.-**

ប្រកាសលេខ ១៧២ បទ.ប្រក ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១០ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ និងគ្រប់អង្គភាពទាំងអស់ក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

ត្រាក់ សុខុន

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ